# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1509

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ផ្នែក ក

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ជំរុញការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និង ម៉ាកសមូហភាពរបស់កម្ពុជា និង ការផ្សព្វផ្សាយការបណ្តុះបណ្តាលទាក់ទងនឹងកម្មសិទ្ធិបញ្ញានិងការលើកកម្ពស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព និង រៀបចំវគ្គបណ្តុះបណ្តាលជាន់ខ្ពស់លើផ្នែកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព ដើម្បីជំរុញកំណើនពាណិជ្ជកម្ម។

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 01/01/27 |
| ៣. ចំណាយគម្រោងសរុប | $945,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងពាណិជ្ជកម្ម |
| RESPONSIBLE UNIT | Department of Intellectual Property |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានកម្មសិទ្ធិបញ្ញា |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងការប្រកួតប្រជែង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះ នឹងចូលរួមចំណែកក្នុងលើកកម្ពស់ចំណេះដឹងដល់សាធារណជន ជាពិសេសវិស័យឯកជន ពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ, ម៉ាកសមូហភាព, ការប្រើប្រាស់ឡូហ្គូ ឬពាណិជ្ជសញ្ញា, នីតិវិធីផ្សេងៗពាក់ព័ន្ធការកសាងកេរ្តិ៍ឈ្មោះម៉ាក, ការរៀបចំផែនការ, ការរៀបចំបង្កើតសមាគម, វិធីសាស្ត្រក្នុងការគ្រប់គ្រង, និងការចាត់ចែងនានាក្រោយពីចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព ដែលនឹងចូលរួមចំណែកជាមួយនឹងគោលនយោបាយបញ្ចកោណ ដំណាក់ទី១ ក្នុងការធ្វើពិពិធកម្មមុខទំនិញរបស់កម្ពុជាសម្រាប់នាំចេញទៅទីផ្សារបរទេស។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? គាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គោលបំណងរបស់គម្រោង ដើម្បីលើកកម្ពស់ចំណេះដឹងសាធារណៈពាក់ព័ន្ធម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព ការរៀបចំចងក្រងសមាគម នីតិវិធីនៃការដំណើរការសមាគម ការគ្រប់គ្រងសមាគម ការរៀបចំវគ្គបណ្តុះបណ្តាលជាន់ខ្ពស់ផ្នែកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាកសមូហភាព និង ការផ្តល់កិច្ចការពារនិងគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម និងកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមចំណែកអភិវឌ្ឍវិស័យកសិកម្ម ពាណិជ្ជកម្ម អភិរក្សវប្បធម៌ និងឱ្យក្លាយទៅជាគោលដៅទេសចរណ៍។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

- ចុះសិក្សា និងស្រាវជ្រាវជាបឋម លើមុខទំនិញសក្តានុពលចំនួន៣ អំពីគុណភាព ផលិត, ចងក្រងក្រុមផលិត/កសិករ, និង ទីតាំងផលិតតើស្របតាមនិយាមនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬ ម៉ាកសមូហភាព
- ចុះផ្សព្វផ្សាយពីអត្ថប្រយោជន៍របស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាកសមូហភាព
- ជួលជំនាញការដើម្បី រៀបចំសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងសៀវភៅបទបញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព និងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជី
- រៀបចំបង្កើតសមាគម និងចុះបញ្ជីនៅក្រសួងមហាផ្ទៃ រៀបចំសៀវភៅបន្ទុក និងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព ចំនួន៣
- រៀបចំមហាសន្និបាតកំណើតដំបូងរបស់សមាគម ឬក្រុមអ្នកផលិត
- រៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកគណៈកម្មាធិការប្រតិបត្តិនៃសមាគមអន្តរវិជ្ជាជីវៈ និងក្រុមអ្នកផលិតម៉ាកសមូហភាព
- រៀបចំវគ្គបណ្តុះបណ្តាលជាន់ខ្ពស់ផ្នែកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាកសមូហភាព
- រៀបចំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រនិងម៉ាកសមូហភាពកម្ពុជាឱ្យបានចំនួន ៣ ពីឆ្នាំ២០២៥-២០២៨

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

ប្រសិនបើគម្រោងនេះត្រូវបានតាក់តែង និងអនុវត្តជោគជ័យ នោះសាធារណជន/សមាគម នឹងទទួលបានចំណេះដឹងជាមូលដ្ឋានទាក់ទងនឹងការប្រើប្រាស់កម្មសិទ្ធិបញ្ញា ជាពិសេសលើផ្នែកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាកសមូហភាពនិង ទទួលបានការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឬម៉ាកសមូហភាពថ្មីចំនួន០៣ ដែលនឹងធ្វើឱ្យកម្ពុជាទទួលបានទំនិញសក្តានុពលបន្ថែមដែលមានតម្លៃបន្ថែមខ្ពស់ និងមានភាពប្រកួតប្រជែង សម្រាប់ធ្វើការនាំចេញទៅកាន់ទីផ្សារពិភពលោក។

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

ជារួម គម្រោងនេះនឹងចូលរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនទូទៅ ធុរជននិងវិនិយោគិន និងកំណើនសេដ្ឋកិច្ចជាតិទាំងមូលព្រមទាំងប្រយោជន៍ផ្សេងៗទៀត ដូចជា៖

- រាជរដ្ឋាភិបាលកម្ពុជា, ក្រសួងពាណិជ្ជកម្ម
- សមាគមនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញឬម៉ាកសមូហភាព
- ប្រជាពលរដ្ឋ

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងមិនមានផលប៉ះពាល់ដល់បរិស្ថាន និងប្រជាជនទេ ប៉ុន្តែនឹងចូលរួមអភិវឌ្ឍជំនាញនិងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន ដែលនឹងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**លើកកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យកម្មសិទ្ធិបញ្ញា។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោង ប៉ុន្តែក៏ត្រូវមានការជួយសហការចូលរួមពីអ្នក ជំនាញជាតិ និងអន្តរជាតិ ដើម្បីធ្វើការបណ្តុះបណ្តាលបន្ថែមផងដែរ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

មិនទាន់មានការអនុវត្តបានពេញលេញនៅឡើយ ដោយសារមិនទាន់មានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

7

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

-ដៃគូអភិវឌ្ឍនានា ដែលមានជំនាញកម្មសិទ្ធិបញ្ញា ឬ ចង់ចូលរួមចំណែកជួយដល់កម្មសិទ្ធិបញ្ញាកម្ពុជា ដូចជា៖ WIPO, KIPO, KIPA, EU ឬ អង្គភាពកម្មសិទ្ធិបញ្ញាបរទេសនានា។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 345.0 | 300.0 | 300.0 | 945.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទិញសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 345.0 | 300.0 | 300.0 | 945.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 345.0 | 300.0 | 300.0 | 945.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 345.0 | 300.0 | 300.0 | 945.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: